# Living the Lotus 10

## Buddhism in Everyday Life

2025
VOL. 241




## Members in the US, and from Japan, Join the 2025 Nisei Week Grand Parade in Los Angeles, August 10




Photo@EricXiong

Living the Lotus
Vol. 241 (October 2025)

Senior Editor: Keiichi Akagawa
Editor: Sachi Mikawa
Copy Editor: Penn Setharin

*Living the Lotus* is published monthly
By Rissho Kosei-kai International,
Fumon Media Center, 2-7-1 Wada,
Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp

រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.




# “សិក្សា” ដោយ “អានសៀវភៅ”

ដោយព្រះគ្រូនីវ៉ាណូ នីជិកុ
ព្រះប្រធានរីហ្សូកូសេកៃ

## ចងមិត្តជាមួយវរជនឬបព្វជិតថ្លៃថ្នូរប្រាជ្ញាខ្ពស់

ឱ្យតែចូលមកដល់រដូវនេះ យើងតែងតែឮឃ្លាថា "សរទរដូវ,រដូវកាលសម្រាប់ការអានសៀវភៅ" នៅក្នុងសេចក្ដីបញ្ចប់នៃអត្ថបទពីខែមុននេះ ខ្ញុំព្រះករុណាអាត្មាភាពបានសរសេរថា "ខ្ញុំព្រះករុណាអាត្មាភាពនឹងសរសេរអំពីការសិក្សារៀនសូត្រឱ្យបានក្បោះក្បាយស៊ីជម្រៅ"។ ក្នុងករណីនេះខ្ញុំព្រះករុណាអាត្មាភាពមានជំនឿថាការអានសៀវភៅគឺជាវិធីដ៏សំខាន់ ហើយងាយស្រួលសម្រាប់ការសិក្សារៀនសូត្រ។

នៅក្នុង "ច្បាប់ទាំងប្រាំពីរសម្រាប់សាមូរ៉ៃ" លោកយោស៊ីដា ហ្សូអ៊ីង (Yoshida Shoin) ដែលជាទស្សនវិទូនៅចុងសម័យអេដូ ( 1603-1868 ) បានផ្ញើសារមួយទៅជូនបងប្អូនជីដូនមួយរបស់គាត់សម្រាប់ពិធីឈានចូលដល់វ័យគ្រប់ការរបស់គេ ( ពេលយុវជនមានអាយុប្រហែល 15 ឆ្នាំ )។នៅក្នុងសារនោះ យោស៊ីដា ស្ហូអ៊ីងបានសរសេរថា" ខណៈពេលដែលរស់នៅជាមនុស្សបើអ្នកមិនយល់ពីការពិតនៃអតីតកាលនិងបច្ចុប្បន្ន - បើអ្នកមិនរៀនសូត្រពីវរជនឬបព្វជិតអ្នកប្រាជ្ញទេអ្នកនឹងក្លាយជាមនុស្សដែលគិតតែពីប្រយោជន៍ផ្ទាល់ខ្លួនពោលគឺជាមនុស្សថោកទាបមិនថ្លៃថ្នូរ។"

□ហេតុដូច្នេះហើយការរាប់អានជាមួយអ្នកប្រាជ្ញនិងវរជនតាមរយៈការអាន (ការអានគឺជាដៃគូដ៏ប្រសើរ)□ គឺជាកាតព្វកិច្ចរបស់បុគ្គលដែលមានគុណធម៌។ស្ហូអ៊ីងបានសង្កត់ធ្ងន់ទៅលើសារៈសំខាន់ដ៏អស្ចារ្យនៃការអានសៀវភៅដើម្បីស្វែងយល់អ្វីមួយឱ្យបានស៊ីជម្រៅ។

ជាការពិតណាស់មិនបាច់ចាំកំណត់ចំពោះតែការបង្រៀនរបស់អ្នកប្រាជ្ញតែប៉ុណ្ណោះទេ; សៀវ ភៅគ្រប់ប្រភេទអាចបង្រៀនយើងអំពីអារម្មណ៍ និងអាចកំបាំងដ៏គួរឲ្យរំភើប ព្រមទាំងទុក្ខព្រួយ និងភាពរីករាយរបស់មនុស្ស ហើយសៀវភៅនីមួយៗជាជីវជាតិសម្រាប់ចិញ្ចឹមព្រលឹងមនុស្ស។

ក៏ប៉ុន្តែ សព្វថ្ងៃនេះ ហាងលក់សៀវភៅកាន់តែចុះតិចទៅៗ ហើយអ្នកចូលចិត្តអានសៀវភៅឌីជីថលអាចសើចចំអកឱ្យយើងថា " សម័យនេះហើយនរណាគេទៅអានសៀវភៅក្រដាសទៀតនោះ... "

ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការសិក្សាជាច្រើនបានបង្ហាញថា ការអានសៀវភៅមានអត្ថប្រយោជន៍អស្ចារ្យសម្រាប់រាងកាយ និងចិត្ត ដោយមិនគិតពីអាយុ។

# អត្ថប្រយោជន៍នៃការអានសៀវភៅ

យោលទៅតាមការសិក្សាមួយ នៅពេលដែលមនុស្សអានរឿង គេបណ្តែតអារម្មណ៍ស្រមើស្រមៃមើលទៅពិភពលោកដែលនៅក្នុងរឿងនោះ ឬក៏ចូលតួជាមួយតួអង្គ។នៅពេលនោះ គេក៏យល់ដឹងអំពីខ្លួនគេផ្ទាល់ ហើយជាមួយគ្នានោះដែរ កត្តានេះជំរុញឱ្យមានការយល់ចិត្ត យល់អារម្មណ៍និងមានសមានចិត្ត ព្រមទាំងអាចបណ្តុះនូវមនោសញ្ចេតនាចំពោះអ្នកដទៃផងដែរ។ មានទិន្នន័យដែលបង្ហាញថាចំនួនវាក្យស័ព្ទរបស់កុមារដែលចូលចិត្តអានសៀវភៅមានច្រើនជាងកុមារដែលមិនចូលចិត្តអានដល់ទៅបីដង។

អតីតនាយករដ្ឋមន្ត្រីអង់គ្លេស លោកតូនី ប្លែរ (Tony Blair) បាននិយាយថា"ចំនួនសៀវភៅដែលកុមារអាយុប្រាំពីរឆ្នាំអាននឹងកំណត់តម្លៃសម្បទានៃអត្ថិភាពរបស់ចក្រភពអង់គ្លេសនាម្ភៃឆ្នាំក្រោយចាប់ពីពេលនេះតទៅ"។ មានន័យថាប្រទេសដែលមានមនុស្សដែលមានតុល្យភាពរវាងការអភិវឌ្ឍន៍ផ្លូវចិត្តនិងបញ្ញាតាមរយៈការអានសៀវភៅ គឺជាប្រទេសដែលមានមនុស្សមានការអប់រំល្អ ថ្លៃថ្នូរ ស្លូតបូត និងរួសរាយរាក់ទាក់ ដែលជាកត្តាសម្រាប់ធ្វើឱ្យប្រទេសនោះក្លាយជាប្រទេសដ៏មានឥទ្ធិពល។

តាមរយៈស្មាតហ្វូន និងឧបករណ៍ផ្សេងទៀត យើងទទួលបាន"ព័ត៌មាន"ប៉ុន្តែគណិតវិទូ ហ្វូជីវ៉ារ៉ា ម៉ាសាហ៊ីកុ (Fujiwara Masahiko) និយាយថា "មានតែតាមរយៈការអានសៀវភៅទេដែលព័ត៌មានដាច់ដោយឡែកពីគ្នាត្រូវបានរៀបចំជាប្រព័ន្ធឱ្យទៅជាចំណេះដឹង ហើយចំណេះដឹងនោះត្រូវបានរៀបចំឱ្យទៅជាប្រព័ន្ធតាមរយៈបទពិសោធន៍ ការពិចារណា និងមនោសញ្ចេតនាហើយក្លាយជាវប្បធម៌របស់មនុស្សម្នាក់ៗ"។(ដកស្រង់ចេញពីសៀវភៅ『ចូរនាំគ្នាការពារបណ្ណាគារ(本屋を守れ)』／វិទ្យាស្ថានស្រាវជ្រាវPHP)

ក្រៅពីនេះ "ការអានសៀវភៅក្រដាស" មានអត្ថប្រយោជន៍ជាច្រើនទៀតដូចជាមានឥទ្ធិពលបន្ធូរអារម្មណ៍ កាត់បន្ថយស្ត្រេស និងធ្វើឱ្យជម្ងឺវង្វេងបានកែលំអ ប៉ុន្តែសំខាន់ជាងនេះទៅទៀត យោលទៅតាមការអានសៀវភៅ (ឬគម្ពីរ)យើងអាចទទួលបានការបង្រៀនប្រៀនប្រដៅពីព្រះសម្មាសម្ពុទ្ធឬខុងជឺ ។ កាលណាយើងអានជីវប្រវត្តិឬបទពិសោធន៍ជីវិតនៃមនុស្សនានាកាន់តែច្រើន យើងក៏កាន់តែមានសេចក្តីអំណរកាន់តែច្រើនក្នុងការដឹងពីបទពិសោធន៍ក្នុងជីវិតរបស់អ្នកដទៃ។

អ្វីដែលពិសេសជាងនេះទៅទៀតឱកាសប្រា ស្រ័យទាក់ទងជិតស្និទ្ធជាមួយនឹងសៀវភៅក្រដាសមានសារៈសំខាន់ខ្លាំងណាស់ចំពោះកុមារតូចៗ ដែលនឹងក្លាយជាអ្នកដឹកនាំជំនាន់ក្រោយ ។ អារម្មណ៍ដែលប៉ះពាល់ជាមួយនឹងសៀវភៅមួយក្បាល សំឡេងហើយនិងពាក្យរបស់ឪពុកម្តាយដែលអានឱ្យពួកគេស្តាប់ សុទ្ធតែជួយអភិវឌ្ឍខួរក្បាលរបស់ពួកគេ និងជំរុញចំណេះដឹង និងមនោសញ្ចេតនាជាមនុស្សរបស់ពួកគេ។

ខ្លួនខ្ញុំព្រះករុណាអាត្មាភាពផ្ទាល់ក៏ចូលចិត្តអានដោយសង្ឃឹមថានឹងរៀនពីរបៀបរស់នៅជាមនុស្ស និងអភិវឌ្ឍបេះដូងរបស់ខ្លួន ប៉ុន្តែនៅពេលដែលកូនៗនៅតូច ខ្ញុំព្រះករុណាអាត្មាភាពតែងតែងងុយគេងពេលអានសៀវភៅឲ្យពួកគេស្តាប់មុនពេលចូលគេង។ ទោះជាយ៉ាងណាក៏ដោយខ្ញុំព្រះករុណាអាត្មាភាពជឿថាពេលវេលាទាំងនេះក៏ជា "ការចងចាំនូវការអាន" ដ៏សំខាន់ ដែលចិញ្ចឹមមនោសញ្ចេតនាឪពុកម្តាយនិងកូនផងដែរ។

ក្នុងករណីណាក៏ដោយ យោលតាមទស្សនៈនៃការដុសខាត់កែលម្អខ្លួនឯង និងការបណ្តុះបណ្តាលអ្នកដទៃ យើងគួរតែធ្វើឱ្យការ "រៀនសូត្រ" តាមរយៈ "ការអានសៀវភៅ" ទៅជាសេចក្តីរីករាយរបស់យើងនារាត្រីនៃរដូវស្លឹកឈើជ្រុះដ៏វែង ហើយធ្វើឱ្យវាក្លាយជាទម្លាប់ប្រចាំថ្ងៃមួយរបស់យើង។

From Kosei, October 2025






# A Global Buddhist Movement




**Information about local Dharma centers**

**facebook**

**X**

We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp